**មាត្រា ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិង សន្តិសុខ ជាតិ ទាក់ទងនិងអោទិការ នៃកងយោធពលខេមរភូមិន្ទ ឯកឧត្តម សក់ ស៊ុតសាខន និង សាមីខ្លួនដែលមាននាម ក្នុងមាត្រា ១ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃ ឡាយព្រះហស្ថ លេខា និ ងតទៅ ។

**នាយករដ្ឋមន្ត្រីទី១**
ព្រះហស្តលេខា
ព្រះអង្គម្ចាស់ក្រុមព្រះ **នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

* * * *

## ២ . សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣

### សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិរៀបចំទឹកដីនិងគោលការណ៍នគរូបនីយកម្មសំរាប់ តំបន់ជុំវិញ ភ្នំពេញ និង ខេត្ត ក្រុងទូទាំងប្រទេស

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកតាមសំណូមពរការងារចំបាច់

**សំរេច**

**ប្រការ ១ ៖** បង្កើតគណៈកម្មាធិការជាតិមួយហៅឈ្មោះថា " គណៈកម្មាធិការជាតិរៀបចំទឹកដី និង គោល ការណ៍ នគ រូបនីយកម្មតំបន់ជុំវិញក្រុងភ្នំពេញ និង ខេត្ត ក្រុងទូទាំងប្រទេស " គណៈកម្មាធិការជាតិនេះ មាន

សមាសភាពដូចតទៅ :

១_ ឯកឧត្តម ខណ្ឌ មូលីខណ្ឌ ទេសរដ្ឋមន្ត្រី ប្រធាន

២_ ឯកឧត្តម គង់ សំអុល រដ្ឋមន្ត្រីក្រសួងកសិកម្ម សមាជិក

៣_ ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក

៤_ ឯកឧត្តម អេង វ៉ាឡង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក

**ប្រការ ២** : គណៈកម្មាធិការជាតិដូចកំណត់ក្នុងប្រការមួយ មានភារកិច្ចដូចតទៅ :

១_ ការពារអ្វី ។ ដែលជាមូលដ្ឋានធម្មជាតិ នៃការរស់នៅរបស់ប្រជារាស្ត្រ ដូចជា ដី ទឹក អាកាស ព្រៃឈើ ទេសភាព ។ល។

២_ បង្កើតគោលនយោបាយលើកកំពស់ស្មារតី ប្រជារាស្ត្រអោយរួមចំណែកក្នុងការអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌តាមខេត្ត ក្រុង ។

៣_ សិក្សាស្រាវជ្រាវអោយមានប្លង់មេ តាមទីប្រជុំជនក្នុង ខេត្ត ក្រុងនីមួយ ។ដើម្បីបំរើគោលដៅគ្រប់វិស័យ ។

៤_ តាមដានពិនិត្យការសាងសង់គ្រប់ប្រភេទមានរោងចក្រ សណ្ឋាគារ ភោជនីយដ្ឋាន ... ដ្ឋានផ្សារ កន្លែងលក់ដូរ ។ល។ អោយបានសមស្របតាមលំនាំទេសភាពនៅទីនោះ ។

៥_ រៀបចំបែងចែកកំណត់តំបន់បំរុងទុកសំរាប់អភិវឌ្ឍន៍តាមវិស័យនីមួយៗ អោយបានសមស្របតាមប្លង់មេ ។

៦_ ការពារ និង ថែរក្សាអោយនៅទំនេរ នូវផ្ទៃដី ជុំវិញត្រពាំង បឹងបួរ ព្រែក ប្រឡាយ ... ជូនប្រជារាស្ត្រងាយស្រួលក្នុងការធ្វើដំណើរ និង ប្រើប្រាស់ទឹក ។

៧_ រក្សាតំបន់ធម្មជាតិ តំបន់ព្រៃឈើ និង កន្លែងរមណីយដ្ឋាន ។

៨_ កំណត់តំបន់សំរាប់សាងសង់លំនៅដ្ឋាន សំរាប់សំណង់បំរើការងារសេដ្ឋកិច្ច តំបន់ឧស្សាហកម្ម តំបន់សំរាប់សម្លាប់សត្វ ស្របតាមតម្រូវការរស់នៅប្រជារាស្ត្រដោយរៀបចំអោយមានប្រព័ន្ធលូទឹក ភ្លើង គមនាគមន៍ដឹកជញ្ជូនបានគ្រប់គ្រាន់ និងរក្សាបរិស្ថានបានល្អ ដូចជា ការបំបាត់ ជាតិពុលក្នុងអាកាស បន្ថយសំលេងខ្លាំង និង ការពុលផ្សេងៗ ។

៩_ ហាមឃាត់ការបោះទីតាំង និង ការសាងសង់តាមទីសាធារណៈ និង ទីកន្លែងបំរើ ការងារសាធារណៈ ដូចជា សាលារៀន ទីលានកីឡា សួនឧទ្យាន វត្តអារាម គិលានដ្ឋាន ទីប្រជុំជន តាមដងផ្លូវរថភ្លើងតាមប្រឡាយទឹកសាធារណៈ ។ល។

សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីលើកគំរោងគោលការណ៍ និងធ្វើពង្រាងច្បាប់ផ្សេង ៗ ដែលពាក់ព័ន្ធនឹងការរៀបចំរដ្ឋធានីភ្នំពេញ និងខេត្ត ក្រុង ដើម្បីដាក់ជូនរដ្ឋាភិបាលពិនិត្យ និងសំរេច មុនសុំការអនុម័តពីរដ្ឋសភា ។

១០ - អប់រំប្រជារាស្ត្រអោយយល់ច្បាស់លាស់នូវករណីយកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ ៗ ដែលមាន ភារកិច្ចរួមចំណែកក្នុងការកសាង ការពារ ថែរក្សាបរិដ្ឋាន និងសោភ័ណភាព ទេសភាពនៅទីក្រុង ក៏ ដូចជានៅជនបទដែរ ។

**ប្រការ ៣** : គណៈកម្មាធិការជាតិមានសិទ្ធិចាត់តាំងលេខាធិការដ្ឋានប្រតិបត្តិមួយប្រចាំនៅទីស្តីការនាយករដ្ឋមន្ត្រី ដើម្បីជំនួយក្នុងការងារ ។

**ប្រការ ៤** : នៅតាមខេត្ត និងក្រុងនានា ក្រៅពីក្រុងភ្នំពេញ ត្រូវរៀបចំអោយមានអនុគណៈកម្មាធិការរបស់ខ្លួនដែល ដឹកនាំដោយអភិបាលខេត្ត ក្រុងផ្ទាល់ ដើម្បីទទួលអនុវត្ត និងធ្វើរបាយការណ៍រាល់ការ ដឹកនាំ ណែនាំរបស់គណៈកម្មាធិការជាតិ ដូចចែងក្នុងប្រការ ២ បានទាន់ពេលវេលា ។

**ប្រការ ៥** : គណៈកម្មាធិការជាតិនេះ មានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ អន្តរជាតិ អង្គការសាធារណៈ អង្គការមូលនិធិតំបន់ ដើម្បីស្នើសុំជំនួយជាថវិកា ក្នុងការធ្វើអោយសម្រេចនូវ រាល់គំរោង និងទិសដៅ ដូចបានរៀបរាប់ខាងលើ និងមានសិទ្ធិកំរិតកំណត់ ក្នុងការប្រើប្រាស់ ថវិកា ដែលបានមកពីជំនួយឧបត្ថម្ភពីកិច្ចសហប្រតិបត្តិការនេះ តាមការកំណត់ចាំបាច់ ។

**ប្រការ ៦** : គណៈកម្មាធិការជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៧** : សេចក្តីសំរេចណាដែលមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកនិរាករណ៍ ។

**ប្រការ ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័ន អភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដូចចែងក្នុងប្រការ ១ មានភារកិច្ចទទួលអនុវត្តតាម ស្មារតីនៃសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

**រាជរដ្ឋាភិបាលនៃកម្ពុជា**

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា ហត្ថលេខា និង ត្រា

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ហ៊ុន សែន